# ជីវប្រវត្តិរបស់ អ៊ីម៉ាំ អាល់-ម៉ាស់ឌី عجل الله فرجك



សៃយីដ្ ម៉ាស់ឌី អាយ៉ាទុលឡ៍ហ៊ី

ស្វាគីប បេនបេឌីរ៉ា

*ផលិតផលចំណីអាហារ ដែលមានចំនួនលើសទៅក្នុងសមុទ្រដើម្បីនឹងកុំឲ្យតម្លៃចុះថោក ។ អាវុធបាក់តេរី អាវុធអ៊ីដ្រូហ្សែន អាវុធបរមាណូ អាវុធនឺត្រុងនឹងត្រូវបង្កើតឡើង មានប្រយោជន៍តែខាងបំផ្លិចបំផ្លាញពិភពលោកតែម្យ៉ាង ។ ផែនដីពោរពេញដោយអំពើខុសឆ្គង អយុត្តិធម៌និងវិនាសអន្តរាយ ។ មនុស្សរង់ចាំបុគ្គលដែលនឹងរំដោះពួកគេឲ្យរួចផុតពីបញ្ហាទាំងនេះ គឺអ៊ីម៉ាំអាល់–ម៉ាស់ឌី عجل الله فرجك ។ សូមអល់ឡោះហ៊្ញ عز وجل ឲ្យព្រះអង្គ عجل الله فرجك ឆាប់ងើបឡើង ។*

## អត្តសញ្ញាណរបស់អ៊ីម៉ាំអាល់-ម៉ាស់ឌី عجل الله فرجك

*-ព្រះនាម ៖ មូហាំម៉ាដ់, អាល់–ម៉ាស់ឌី, អាប៊ូ អាល់–ក៏ស៊ីម ។*

*-ព្រះនាមព្រះបិតា ៖ អ៊ីម៉ាំអាល់–ហាសាន់ អាល់–អាស់ការី صلوات الله عليه والسلام ។*

*-ព្រះនាមមាតា ៖ ណារយ៉ើស ។*

*-ថ្ងៃប្រសូត ៖ ថ្ងៃទី ១៥ ខែស្ហាក់បាន់ ឆ្នាំ ២៥៥ សករាជហ៊ីជ្រ៉េះត៍ ។*

ٱلْحَمْدُ لِلَّهِ رَبِّ ٱلْعَٰلَمِينَ

23/08/2016

អា.១៤៣–១៤៤)»

ជាចុងក្រោយ យើងលើកព្រះសាស្ដាអ៊ីសា عليه السلام ជាឧទាហរណ៍ ដែលអល់ឡោះហ្ទុំ عز وجل លើកឡើងទៅលើ កាលពួកយ៉ាហ៊ូឌីចង់សម្លាប់ព្រះអង្គ តែពួកគេបានសម្លាប់មនុស្សផ្សេង ព្រោះតែគិតថាពួកគេបានសម្លាប់អ៊ីសា عليه السلام ហើយអ៊ីសា عليه السلام មានជីវិតនៅឡើយ ។

## យុត្តិធម៌

ផែនដីយើងមានទ្រព្យសម្បត្តិសន្ធឹកសន្ធាប់ លើសពីសេចក្ដីត្រូវការរបស់យើង ។ បើមានការចែករំលែកត្រឹមត្រូវ បញ្ហាទាំងឡាយរបស់មនុស្សនឹងរលាយបាត់អស់ពីផែនដី ។ ផែនដីទាំងមូលច្បាស់ជានឹងប្រែងបំពេមនុស្សៗនឹងទទួលបាននូវអត្ថប្រយោជន៍បានតាមចិត្ត ។ តែកាលណាមារគ្រប់គ្រងទិដ្ឋភាពនិងដឹកនាំមនុស្ស កាលនោះឋានសួគ៌លោកិយនេះក្លាយទៅជាឋាននរកមិនអាចអត់ទ្រាំនៅបាន ។ នឹងមានតែវិនាសអន្តរាយ មានតែការបាក់បែក ខូចខាត ។ ភាពបែតងនឹងទៅជាចំណីភ្លើង នៅសល់តែផេះ ជាប្រផ្នូលនៃទុក្ខវេទនាដែលកើតពីសង្គ្រាម ។ កូនក្មេងត្រូវស្លាប់ឥតប្រយោជន៍ មនុស្សស្លាប់ព្រោះតែខ្វះចំណី ។ ចំណែកមនុស្សឯទៀតដែលត្រូវមារដឹកនាំ ចោល



ការអះអាងសមហេតុសមផលទេ ។ ការរិះគិតសមហេតុសមផលមិនបានអះអាងថារឿងនេះមិនអាចដូច្នេះបាននោះទេ ចំណែកឯប្រវត្តិសាស្ត្រមនុស្សក៏មិនបានថាវាមិនអាចដូច្នេះបានទេដែរ ។ ផ្ទុយទៅវិញ ប្រវត្តិសាស្ត្រមនុស្សបានផ្ដល់ឲ្យយើងនូវឧទាហរណ៍ច្រើន បញ្ជាក់អំពីការមានអាយុវែងបំផុតដែលជាសញ្ញានៃអានុភាពរបស់អល់ឡោះហ៍ عزّ وجلّ ។ គេអាចរំលឹកឡើងវិញបាននូវរឿងព្រះសាស្ដាអល់ឡោះហ៍ عزّ وجلّ នុះហ៍ عليه السلام ដែលមានអាយុលើសពីដប់ប្រាំបីសតវត្ស គឺ៖ លើសពីប្រាំបីសតវត្សមុនបានទទួលព្រះរាជសារ លើសពីប្រាំបួនសតវត្សក្រោយពីបានទទួលព្រះរាជសារ ហើយមានតែអល់ឡោះហ៍ عزّ وجلّ ទេដែលដឹងថាព្រះអង្គបានរស់នៅប៉ុន្មានឆ្នាំ ក្រោយពីទឹកជំនន់ ។ នៅក្នុងព្រះមហាគម្ពីរគួរអាន អល់ឡោះហ៍ عزّ وجلّ បានបង្ហាញឲ្យយើងឃើញថាអាចបន្លាយអាយុមនុស្សបានរហូតដល់ថ្ងៃជំនុំជម្រះ ពេលព្រះអង្គ عزّ وجلّ មានព្រះបន្ទូលអំពីព្រះសាស្ដាយូនុស عليه السلام ដែលនៅក្នុងពោះត្រី ហើយដែលបានបួងសួងអល់ឡោះហ៍ عزّ وجلّ សូមខមាទោស ថា៖ «បើសិនជាគេមិនមែនជាម្នាក់ក្នុងចំណោមអ្នកថ្វាយសេចក្ដីស្ញើចសរសើរទេនោះ គេប្រាកដជានៅក្នុងពោះវារហូតដល់ថ្ងៃរស់ពីស្លាប់វិញជាមិនខាន ។ (ស៊ី.៣៧,

ចាំឲ្យបណ្ដាសាវកព្រះអង្គឈានដល់សុក្រឹតភាព ។ តែមុស្លីមទាំងអស់រង់ចាំព្រះអង្គទេ ? ឬក៏ពួកគេដូចពួកគ្រិស្តនិងពួកយ៉ាហ៊ូឌីមុនពួកគេដែរ ?

## អាយុរបស់អាល់-ម៉ាស់ឌី عجل الله فرجك អាយុកាលរបស់ការរង់ចាំ

វិវាទកម្មក្នុងរឿងអ៊ីម៉ាំអាល់-ម៉ាស់ឌី عجل الله فرجك ក្នុងចំណោមពួកមុស្លីម គឺមុស្លីមមួយចំនួនមិនព្រមប្រតិបត្តិតាមហាឌីស្ហរបស់ព្រះសាស្ដា صلى الله عليه وآله وسلم ទេ ដែលស្ដីអំពីអ៊ីម៉ាំអាស់លុល-បៃត៍ عليهم السلام ទីដប់ពីរនោះ ។ តើមុស្លីមទាំងអស់ព្រមទទួលស្គាល់ថាហាឌីស្ហនេះជាហាឌីស្ហពិតទេ គឺ៖ «អ្នកស្នងទាំងឡាយ អត់ពីខ្ញុំទៅមានដប់ពីរនាក់ ហើយទាំងអស់គ្នាជាពូជពង្សគូរ៉យស្ហ៍ ។»

បុគ្គលទាំងដប់ពីរនាក់នេះជាអ្នកណា ? ការបកស្រាយប្លែកៗមិនខ្វះទេ ។ មានតែពួកស្ហ៊ីអ៊ាស្ទ៍ដែលតាមអាស់លុល-បៃត៍ عليهم السلام ទេ ដែលស្គាល់ការពិតហើយបញ្ជាក់ប្រាប់មនុស្សទាំងអស់ថា មិនមានអ្នកណាដែលសក្តិសមជាអ្នកស្នងព្រះសាស្ដា صلى الله عليه وآله وسلم ជាងអ៊ីម៉ាំអាស់លុល-បៃត៍ عليهم السلام ទាំងដប់ពីរទេ ។ លុះការពិភាក្សាឈានដល់អ៊ីម៉ាំទីដប់ពីរ ពួកអ្នកប្រឆាំងអ៊ីម៉ាំទាំងដប់ពីរលើកបញ្ហាអាយុរបស់ព្រះអង្គ ពល់គ្រា មកនិយាយព្រោះពួកគេគិតថាអាយុរបស់អ៊ីម៉ាំទីដប់ពីរវែងពេកដើម្បីចាត់ទុកជាការពិតនោះ ។ តែរឿងនេះមិនស្ថិតនៅលើ

# បញ្ជីមាតិកា


១-កំណើតសម្ងាត់របស់អ៊ីម៉ាំ عجل الله فرجك ....6
សេចក្ដីភ័យខ្លាចឥតខ្លឹមសាររបស់ពួកអាប់បាស់....6
កំណើតនៃសេចក្ដីសង្ឃឹម ....11
ណារយ៉ីស (نرجس)....12
១-ជីវប្រវត្តិរបស់អ៊ីម៉ាំម៉ាស់ឌី عجل الله فرجك ....15
ដំណាក់កាលទី ១ ជាមួយព្រះបិតាព្រះអង្គ....15
ដំណាក់កាលទី ២ បន្ទាប់ពីព្រះបិតាចូលទិវង្គត....16
ដំណាក់កាលទី ៣ រហស្សកម្មធំ ....18
ព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រ....21
៣-ការទន្ទឹងចាំដ៏យូរ ....23
ការរង់ចាំ ....23
ការលេចឡើងរបស់អ៊ីម៉ាំអ៊ីម៉ាំអាល់-ម៉ាស់ឌី عجل الله فرجك ....25
អាយុរបស់អាល់-ម៉ាស់ឌី عجل الله فرجك អាយុកាលរបស់ការរង់ចាំ ....28
យុត្តិធម៌....30
អត្តសញ្ញាណរបស់អ៊ីម៉ាំ صلوات الله عليه والسلام ....31

# ១-កំណើតសម្ងាត់របស់អ៊ីមុាំ عجل الله فرجك

## សេចក្ដីភ័យខ្លាចឥតខ្លឹមសាររបស់ពួកអុាប់បាស់

អ៊ីមុាំទី ១២ សូមអល់ឡោះហ៊្វ عز وجل ឲ្យព្រះអង្គឆាប់លេចឡើង បានប្រសូតថ្ងៃទី ១៥ ខែស្ហាក់បាន់ ឆ្នាំ ២៥៥ សករាជហ៊ិជ្ជរ៉ោះត៏ ។ កំណើតព្រះអង្គធ្វើឲ្យជនក្រីក្រនិងជនដែលត្រូវគេសង្កត់សង្កិនមានសេចក្ដីសង្ឃឹមឡើងវិញ ។ ព្រះបិតាព្រះអង្គគឺអ៊ីមុាំអាល់-អុាស់ការី صلوات الله عليه والسلام ។ មាតាព្រះអង្គមាននាមថា ណារយ៉ិស (نرجس) ជាវង្សត្រកូលរបស់សាំអ៊ុន អ្នកជម្រះបន្ទុទ្ធ សាវកម្នាក់របស់ព្រះសាស្ដាអ៊ីសា عليه السلام ។ អាល់-ម៉ាស្ទ័ឌី عجل الله فرجك ជាអ៊ីមុាំអាស្ទ័លុល-បៃត៏ عليهم السلام ចុងក្រោយបង្អស់ ។ កាលពីរបីសតវត្សមុន ព្រះសាស្ដា صلى الله عليه وآله وسلم បានទាយជាមុនអំពីកំណើតព្រះអង្គនៅក្នុងហាឌីស្ទជាច្រើនថាៈ «កូនចៅខ្ញុំម្នាក់នឹងចាប់កំណើត ។ គេនឹងធ្វើឲ្យផែនដីពោរពេញដោយយុត្តិធម៌បន្ទាប់ពីវាបានពោរពេញដោយអយុត្តិធម៌ និងអំពើខុសឆ្គង ។ ឈ្មោះរបស់គេគឺមូហ៊ាំម៉ាដ្ទ័ ឈ្មោះខ្លួនគេគឺ អាល់-ម៉ាស្ទ័ឌី (مَهْدِيّ) គារវនាមរបស់គេគឺ អាប៊ូអាល់-ក៏ស៊ិម (أبو القاسم) ។

ព្រះអង្គជាទារកដែលគេបានទទួលបញ្ជាឲ្យចាប់ខ្លួន តាំងពីមុនចាប់កំណើតម៉្លេះ ។ ពួកចារបុរសរបស់ស្ដេចខ៏លិហ្វសម័យនោះត្រួតពិនិត្យគ្រប់





គេជាមានគុណសម្បត្តិដូចអ៊ីម៉ាំអាល់–ម៉ាស់ហ្ទី عجل الله فرجك ដែរ ។ ពួកអ្នកកាន់សាសនាគ្រិស្តជឿថាមានការលេចឡើងដូចនេះដែរ ។ សម្រាប់ពួកគេព្រះយេស៊ូគ្រិស្តនឹងត្រឡប់មកឯផែនដីវិញដើម្បីធ្វើឲ្យ យុត្តិធម៌និងសន្តិសុខសោយរាជ្យលើផែនដី ។ ពួកកាន់សាសនាស៊ូរ៉ូឌ្ទស្ទទីយ៉ាស់ (زرادشتية) ជឿដែរថាមានអ្នករំដោះម្នាក់ ក្នុងចំណោមបណ្តាកូនចៅរបស់ស៊ូរ៉ូទុស្ទតា (زرتشت) ។

បែរមកស្តីអំពីព្រះរាជសារវិញ គេឃើញថាព្រះសាស្តាទាំងអស់បានព្យាករព្រឹត្តិការណ៍នេះ គឺ៖ អ្នកសង្គ្រោះមនុស្សពីការគៀបសង្កត់និងអំពើអយុត្តិធម៌ ។ មូសា ﵇ បានព្យាករថាអ៊ីសា ﵇ នឹងចេញមក អ៊ីសា ﵇ បានព្យាករថាមូហាំម៉ាដ់ ﷺ នឹងចេញមក មូហាំម៉ាដ់ ﷺ បានទាយថាអាល់–ម៉ាស់ហ្ទី عجل الله فرجك នឹងលេចខ្លួនឡើង ។ តែទាំងពួកយ៉ាហ៊ូឌី ទាំងពួកគ្រិស្តមិនព្រមទទួលស្គាល់ទេថាទំនាយរបស់សាស្តារបស់ពួកគេនោះនឹងបានសម្រេចទេ ។ រីឯមូស្លីមភាគច្រើននៅក្នុងការរង់ចាំមិនច្បាស់លាស់ លើកលែងតែពួកស៊ីអ៊ីអាស់ទេ ។ តែក្នុងអំឡុងពេលនេះ បុគ្គលដែលគេរង់ចាំ អាល់–ម៉ាស់ហ្ទី عجل الله فرجك ពិតអ្នកសង្គ្រោះ អ្នករំដោះមនុស្ស រស់នៅជាមួយយើង ព្រះអង្គមើល ស្តាប់និង



សព្វក្នុងជីវភាពរស់នៅរបស់គ្រួសារព្រះអង្គ ។ ធ្លបបានទទួលបញ្ជាឲ្យត្រួតពិនិត្យមហេសីទាំងឡាយរបស់អ៊ីម៉ាំអាល់–អ៊ាស់ការី صلوات الله عليه والسلام ដើម្បីបង្ការកំណើត ។ រាល់គ្រាដែលមហេសីណាទ្រង់គភ៌ គេរង់ចាំពេលប្រសូតដើម្បីពិនិត្យមើលភេទទារក ។ ពួកចារបុរសបានទទួលបញ្ជាឲ្យសម្លាប់ទារកប្រុសៗ ។ នេះគឺប្រវត្តិរបស់ព្រះសាស្តាមូសា ﵇ ដែលបានកើតឡើងម្តងទៀត ដូចព្រះសាស្តា ﷺ បានទាយទុកមុនមែន ។ មិនមែនជាចៃដន្យទេដែលមួយភាគបីនៃព្រះគម្ពីរគួរអាន ជាប់ពាក់ព័ន្ធនឹងប្រវត្តិរបស់ណាប៊ីមូសា ﵇ និងពួកយ៉ាហ៊ូឌីនោះ ពីព្រោះព្រឹត្តិការណ៍ដែលបានកើតឡើងរួចមកហើយនឹងកើតឡើងម្តងទៀតជាមួយពួកមូស្លីម ដូចព្រះសាស្តា ﷺ ផ្ទាល់បានបញ្ជាក់នៅក្នុងហាឌីស្ហមួយ ។

អល់ឡោះហ៍ عز وجل បានសម្រេចឲ្យអ៊ីម៉ាំអាល់–ម៉ាស់ហ្ទីប្រសូតនិងធាត់ធំ ទោះជាត្រូវស្តេចខ៏លិហ្វសម័យនោះបានត្រួតពិនិត្យនិងឃ្លាំមើល យ៉ាងតឹងរ៉ឹងក៏ដោយ ។

ថ្ងៃដែលអ៊ីម៉ាំអាល់–ម៉ាស់ហ្ទី عجل الله فرجك ប្រសូត ពួកភ្នាក់ងាររបស់ស្តេចខ៏លិហ្វបានរុករានចូលមកក្នុងដំណាក់អ៊ីម៉ាំអាល់–អ៊ាស់ការី صلوات الله عليه والسلام បានឆែកឆេរគ្រប់

ទីកន្លែងតែមិនបានប្រទះឃើញអ្វីទេ ព្រោះអ៊ីម៉ាំបានប្រុងប្រយ័តជាមុនដើម្បីកុំឲ្យរកព្រះរាជកុមារឃើញ ។ ក្រៅពីជំនិតឯកមួយចំនួនតូច មិនមានអ្នកណាដឹងរឿងនេះទេ ។ ដូច្នេះពួកសត្រូវមិនដឹងថាបុគ្គលអ្នករំដោះមនុស្សជាតិបានប្រសូតហើយឬទេ ។

អ៊ីម៉ាំហាសាន់ អាល់–អ៊ាស់ការី صلوات الله عليه والسلام ព្រះបិតារបស់អ៊ីម៉ាំអាល់–ម៉ាស់ឌី عجل الله فرجك បានចូលទិវង្គតក្នុងឆ្នាំ ២៦០ សករាជហ៊ិជ្ជរ៉ោះត្ន៍ ដោយបន្សល់ទុកនូវព្រះរាជបុត្រព្រះអង្គតែមួយអង្គគត់ ដែលមានព្រះជន្មាយុប្រាំវស្សា ទទួលបន្ទុកដ៏ធ្ងន់បំផុតដែលមិនមានបុគ្គលណាមួយក្នុងលោកអាចទ្រួច ។ ការពិតអល់ឡោះហ៍ عز وجل មានព្រះបំណង ឲ្យបុគ្គលអ្នកប្រតិបត្តិតុលាការព្រះអង្គនោះជាអ៊ីម៉ាំតាំងពីក្មេងវ័យម្ល៉េះ ដូចព្រះសាស្តាយ៉ាស៊ុយ៉ា عليه السلام ដែរ ។ មែន ព្រះសាស្តា عليه السلام យ៉ាស៊ុយ៉ា عليه السلام បានទៅជាសាស្តាតាំងពីក្មេងវ័យម្ល៉េះ ដើម្បីប្រកាសព្រះរាជសាររបស់អ៊ីសា عليه السلام អ៊ីសា عليه السلام ជាព្រះសាស្តារបស់អល់ឡោះហ៍ عز وجل តាំងពីនៅជាទារកម្ល៉េះ ។

ក្នុងចន្លោះពេលនោះ ស្តេចខ៍លិហ្វត្រកូលអ៊ាប់បាស់មិនអាចអត់ទ្រាំព្រះកេរ្តិ៍ឈ្មោះដ៏ល្បីរន្ទឺរបស់អ៊ីម៉ាំហាសាន់ អាល់–អ៊ាស់ការី صلوات الله عليه والسلام តទៅទៀតបាន ក៏



ទាំងអស់ដែលទាក់ទងនឹងអ្នកសង្គ្រោះមនុស្សជាតិ យ៉ាងយកចិត្តទុកដាក់ គឺ៖ ថ្ងៃកំណើតរបស់ព្រះអង្គ កុមារភាពរបស់ព្រះអង្គ រហស្សកម្មដំបូងរបស់ព្រះអង្គ រហស្សកម្មធំរបស់ព្រះអង្គ ការជួបរាំងព្រះអង្គនិងបណ្តាសាវកព្រះអង្គសំបុត្រព្រះអង្គផ្ញើទៅអ្នកតំណាងព្រះអង្គ ។ល ។

រហស្សកម្មធំមិនមានន័យថាចោលការទទួលខុសត្រូវសំខាន់ៗ ដែលជាកាតព្វកិច្ចរបស់មុស្លីមគ្រប់រូបនោះទេ តែជាការពង្រឹងជំនឿនិងសេចក្តីទុកចិត្តលើអល់ឡោះហ៍ عز وجل តទៅជានិច្ច និងជាការអប់រំខ្លួនឲ្យកាន់តែសុក្រឹតឡើងដើម្បីសក្តិសមជាបម្រើរបស់អាល់–ម៉ាស់ឌី عجل الله فرجك ដែលគេរង់ចាំនោះ ។

## ការលេចឡើងរបស់អ៊ីម៉ាំអាល់-ម៉ាស់ឌី عجل الله فرجك

មិនមានតែពួកមុស្លីមទេដែលរង់ចាំបុគ្គលកម្ចាត់អំពើអយុត្តិធម៌ ចេញមកនោះ ដើម្បីធ្វើឲ្យសមធម៌និងយុត្តិធម៌សោយរាជ្យពេញផែនដី ។ សាសនាទាំងអស់ជឿលើបុគ្គលនេះដែរ ។ ពួកយ៉ាហ៊ូឌីដែរជឿថាអាល់–ម៉ាស៊ិះហ៍ (المسيح) នឹងចេញមក ហើយពួកគេរង់ចាំ ។ លុះអ៊ីសា عليه السلام ចេញមក ពួកគេបានស៊ុមគ្រលុំគ្នាសម្លាប់ព្រះអង្គ عليه السلام ។

សព្វថ្ងៃនេះ ពួកយ៉ាហ៊ូឌីមួយចំនួននៅតែរង់ចាំអាល់–ម៉ាស៊ិះហ៍ដែលពួក







បានបញ្ជាឲ្យលួចធ្វើគុតព្រះអង្គ صلوات الله عليه والسلام ។

បុរសឃោរឃៅភ្ញាក់ផ្អើលណាស់ ដែលបានឃើញមហាជនកាន់ទុក្ខមរណៈកម្មអ៊ីម៉ាំអាល់-អ៊ាស់ការី صلوات الله عليه والسلام ជាទូទៅ នៅក្នុងទីផ្សារទាំងឡាយ ជាការសម្តែងឲ្យឃើញថាប្រជារាស្ត្រគោរពអ៊ីម៉ាំណាស់ ដែលត្រូវគេសង្កត់សង្កិននិងឃុំឃាំង ។ តែពិធីបុណ្យសពនេះក៏ជាការបង្ហាញនូវការស្អប់ខ្ពើមទៅលើអំណាចអាប់បាស់អយុត្តិធម៌និងមិនស្របច្បាប់ ។

ខណៈដែលគេដើរហែព្រះរាជសពយ៉ាងយឺតៗ យ៉ាងសោកសៅ ចិត្តក្រៀមក្រំ ទឹកភ្នែកហូរស្រក់សស្រាក់ ពួកចារបុរសរបស់ស្តេចខ៏លិហ្វខ្វល់ខ្វាយតែស្វែងរកសញ្ញា ឬតម្រុយនីមួយដែលអាចជួយឲ្យចាប់ខ្លួនអ៊ីម៉ាំថ្មីបាន ។ ពួកគេដឹងច្បាស់ថា អ៊ីម៉ាំទីដប់ពីរគឺអាល់-ម៉ាស្ហ់ឌី عجل الله فرجك ដែលនឹងកម្ទេចបុគ្គលទុច្ចរិតទាំងអស់ ។

ការខំប្រឹងប្រែងរបស់ស្តេចខ៏លិហ្វមិនបានផលទេ ។ ក្នុងពេលដែលអាល់-ម៉ាស្ហ់ឌី عجل الله فرجك មិនបានលេចខ្លួនឡើងនោះ យ៉ាក់ហ្វារ ប្អូន (ប្អូបង) របស់អ៊ីម៉ាំអាល់-អ៊ាស់ការី صلوات الله عليه والسلام ឆ្លៀតយកឱកាសនេះអះអាងជាអ្នកស្នងបង (ប្អូប្អូន) របស់ខ្លួន ជាអ៊ីម៉ាំថ្មី ។ ពេលធ្វើនមស្ការពិធីបុណ្យព្រះរាជសព គាត់



ដល់ដើមរហេស្យក្រម្មធំ ។

## ៣-ការទន្ទឹងចាំដ៏យូរ

### ការរង់ចាំ

អ្នកតាមអាស្ហ់លុល-បៃត៍ عليهم السلام (ពួកស៊ីអ៊ាស្ហ់) ហៅអ៊ីម៉ាំអាល់-ម៉ាស្ហ់ឌី عجل الله فرجك ថា "អាល់-មុនតាស្ហារ៍" (المنتظر) បុគ្គលដែលគេរង់ចាំ ពោលគឺ បុរសដែលមនុស្សទាំងឡាយចាំឲ្យលេចខ្លួនឡើង ។ គួរកត់សម្គាល់ថា មុស្លីមទាំងអស់ជឿថាបុរសម្នាក់នឹងចេញមកសង្គ្រោះមនុស្ស នឹងធ្វើឲ្យសាសនាអល់ឡោះហ៍ عز وجل សាយភាយលើផែនដីទាំងមូល ហើយនឹងធ្វើឲ្យសត្វលោកទាំងពួងប្រតិបត្តិតាមគុណការអល់ឡោះហ៍ عز وجل ។

ហាឌីស្ហច្រើនរបស់ព្រះសាស្តា صلى الله عليه وآله وسلم ស្តីអំពីហេតុការណ៍ពិតនេះ និងរំលឹកមុស្លីមទាំងឡាយថា ត្រូវត្រៀមខ្លួនចាំមើលកូនចៅព្រះសាស្តា صلى الله عليه وآله وسلم ម្នាក់ដែលមានព្រះនាមដូចព្រះអង្គដែរ ចេញមកធ្វើឲ្យផែនដីពោរពេញដោយយុត្តិធម៌បន្ទាប់ពីវាបានពោរពេញដោយបទអយុត្តិធម៌ ។

តែមានតែពួកស៊ីអ៊ាស្ហ់ អ្នកតាមអាស្ហ់លុល-បៃត៍ عليهم السلام ទេ ដែលចេះបកស្រាយហាឌីស្ហទាំងនេះយ៉ាងច្បាស់លាស់ ហើយពួកគេបានកត់ត្រាទុកអ៊ី

បញ្ជាកុំឲ្យពួកគេយកប្រាក់ទៅដំណាក់ព្រះអង្គ ឲ្យពួកគេទាក់ទងតែតំណាងព្រះអង្គនៅឯបាក់ដាដទេ ។

យ៉ាកុំហ្វារ បុគ្គលឆ្មៀតឱកាស ព្យាយាមដណ្តើមយកប្រាក់នោះដោយសូមជំនួយពីអាជ្ញាធរអុាប់បាស់ ។ អាជ្ញាធរអុាប់បាស់បានចាប់ខ្លួនមាតាអ៊ីម៉ាំ អាល់-ម៉ាស្ទ៍ឌី عجل الله فرجك តែព្រះនាងបដិសេធថាមិនដឹងអ្វីទេ ។

ក្នុងចន្លោះពេលនោះ ប៊ិន ខ័ក្វន់ (بن خاقان) មន្ត្រីរបស់ត្រកូលអុាប់បាស់បានស្លាប់ ។ ការបះបោររបស់ពួកស្បែកខ្មៅបានផ្ទុះឡើង ទាក់ទាញអារម្មណ៍ពួកសាហាវយង់ឃ្នងមកលើពួកគេ ។

ក្នុងអំឡុងរជ្ជកាលស្តេចខ័លិហ្វ អាល់-មុអ្ត៍តាឌ៏ដ្ឋ (المعتضد) តំណាងទាំងឡាយរបស់អ៊ីម៉ាំត្រូវគេសង្កត់សង្កិនខ្លាំងណាស់ ។ ពួកចារបុរសរបស់ពួកអុាប់បាស់ដឹងថាមានអ្វីមួយកើតឡើងតែចាប់ភ័ស្តុតាងមិនបាន ។ ទំនាក់ទំនងរវាងអ៊ីម៉ាំនិងតំណាងទាំងឡាយរបស់ព្រះអង្គកាន់តែរយាលទៅៗ ហាក់ដូចជាព្រះអង្គត្រៀមខ្លួនពួកគេសម្រាប់រហស្សកម្មធំរបស់ព្រះអង្គ ។ ដូច្នេះតំណាងទាំងឡាយរបស់អ៊ីម៉ាំចាប់ផ្តើមចេះដោះស្រាយ ដោយខ្លួនឯង រឿងទូទៅក្នុងសហគមន៍ រហូតដល់ចុងសម័យនេះដែលមានអ្នកតំណាងអ៊ីម៉ាំ និង



បានទៅនៅមុខគេដើម្បីជាអ្នកដឹកនាំពួកគេធ្វើនមស្ការ ។ ត្រង់នេះឯងដែលមានអព្ភូតហេតុអស្ចារ្យមួយកើតឡើងគឺ កុមារតូចម្នាក់បានលេចខ្លួនឡើង រត់សំដៅព្រះរាជសពព្រះបិតា ច្រានមា (ប្អុំ) ចេញ ហើយបានបំពេញនមស្ការឲ្យអ្នកស្លាប់ដោយខ្លួនឯងផ្ទាល់ នៅចំពោះមុខមហាជនដែលអស់សេចក្តីសង្ស័យ ។ ចប់នមស្ការភ្លាម រាជកុមារក៏បានបាត់ខ្លួនយ៉ាងអស្ចារ្យភ្លាមតែម្តងទុកឲ្យមនុស្សទាំងឡាយស្រឡាំងកាំង ។

រាជវង្សាភិបាលអុាប់បាស់ទាល់គំនិត មិនដឹងធ្វើយ៉ាងណា ក្នុងន័យបង្កហេតុក៏បានចែកមរតករបស់អ៊ីម៉ាំអាល់-អុាស់ការី صلوات الله عليه والسلام ដោយខ្លួនឯងផ្ទាល់ ដោយមិនយកចិត្តទុកដាក់នឹងចំណែករបស់ព្រះទាយាទទីមួយទេ គឺអ៊ីម៉ាំ អាល់-ម៉ាស្ទ៍ឌី عجل الله فرجك ។

## កំណើតនៃសេចក្តីសង្ឃឹម

ហ្កាគីម៉ាស្ទ៍ ម្តាយមីង(ប្អូម្តាយធំ)របស់អ៊ីម៉ាំអាល់-អុាស់ការី صلوات الله عليه والسلام បានទៅលេងនឹងព្រះអង្គហើយស្នាក់នៅឯដំណាក់ព្រះអង្គមួយរយៈ ។ ពេលព្រះនាងចង់ត្រឡប់វិញ អ៊ីម៉ាំបានសូមឲ្យព្រះនាងស្នាក់នៅមួយរយៈពេលទៀត ហើយបានប្រាប់ព្រះនាងថា ព្រះនាងណារយ៉ើសនឹងប្រសូតព្រះរាជសន្តបុត្រ

ក្នុងយប់នោះ ។ ព្រះបិតុលានីឆ្ងល់អនេកព្រោះមិនកត់សម្គាល់ឃើញព្រះមហេសីអ៊ីមុាំទ្រង់ព្រះគភ៌ទេ ។ អ៊ីមុាំបានប្រាប់ហ្កាគីម៉ាស្ទ់ថា៖ «នៅពេលមុនថ្ងៃរះ ព្រះនាងនឹងទ្រង់ព្រះគភ៌ (នឹងអាចមើលដឹងថាណារយ៉ីសមានផ្ទៃពោះ) ព្រោះព្រះនាងដូចមាតារបស់មូសា عليه السلام ដែរ ដែលមិនមានអ្នកណាដឹងថាមានផ្ទៃពោះនោះទេលុះដល់ពេលប្រសូតតែម្តង ព្រោះហ្វៀរអ៊ោន لعنه الله វះពោះស្ត្រីមានផ្ទៃពោះគ្រប់រូបដើម្បីកុំឲ្យមូសា عليه السلام ចាប់កំណើតបាន ។ បុត្រខ្ញុំដែលនឹងប្រសូតមកនោះដូចមូសា عليه السلام ដែរ ។»

ហ្កាគីម៉ាស្ទ់បានយាមណារយ៉ីសពេញមួយយប់ ។ លុះដល់ពេលមុនថ្ងៃរះ មហេសីអ៊ីមុាំអស់កម្លាំង ហើយបានប្រសូតបុត្រភ្លាម យ៉ាងងាយស្រួលដោយបានទទួលជំនួយពីព្រះបិតុលានី ។

អ៊ីមុាំអាល់–អ៊ាស់ការី صلوات الله عليه والسلام បញ្ជាសាវកភក្តីឯកម្នាក់របស់ព្រះអង្គ ឈ្មោះអ៊ុម៉ារ ប៊ិន សាអ៊ីដ្ឋ ឲ្យសំឡេះចៀមពីរបី ទិញនំបុ័ងច្រើន ហើយឲ្យយកទៅចែកឲ្យជនក្រីក្រគោកយ៉ាកទាំងឡាយ ។

### ណារយ៉ីស (نرجس)

ណារយ៉ីសជាចៅរបស់ព្រះចៅអធិរាជប៊ីសង់ (byzantine ឬ byzantin) ។



មនុស្សជាតិនោះ រហស្សកម្មនឹងប្រព្រឹត្តទៅទៀត ។

## ព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រ

ប្រតិភូស៊ីអ៊ាស់នៃស្រុកគុមបានមកកាន់ស្រុកសាម៉ារ៉ អ៊ុ ដោយមានសំបុត្រនិងប្រាក់មកឲ្យអ៊ីមុាំហ្កាសាន់ អាល់–អ៊ាសការី صلوات الله عليه والسلام ផង ។ ពេលមកដល់អ៊ីមុាំបានចូលទិវង្គតហើយ ។ ពួកគេក៏បានសួររកទាយាទព្រះអង្គ ។ ពួកភ្នាក់ងាររបស់ពួកអ៊ាប់បាស់បានចង្អុលយ៉ាក់ហ្វារ ប្អូន (ប្អូបង) ព្រះអង្គ ។ ប្រតិភូស៊ីអ៊ាស់ក៏បានទៅសម្តែង ការចូលរួមមរណៈទុក្ខចំពោះយ៉ាក់ហ្វារ ។ ពួកគេបានប្រាប់គាត់ថា៖ «យើងមានសំបុត្រនិងប្រាក់ បើលោកប្រាប់យើងឲ្យស្គាល់អ្នកផ្ញើ យើងនឹងឲ្យសំបុត្រនិងប្រាក់ទាំងនោះទៅលោក ។» យ៉ាក់ហ្វារបានឆ្លើយទាំងកំហឹងថា៖ «ខ្ញុំដឹងបានដូចម្តេចទៅ ?» ពួកគេក៏បានចេញទៅវិញទាំងងឿងឆ្ងល់និងរារែក ។ តំណាងអ៊ីមុាំពិតប្រាកដបានមកតាមពួកគេហើយបានសូមអញ្ជើញពួកគេទៅជួបអ៊ីមុាំអាល់–ម៉ាស្ទ់ឌី عجل الله فرجه អ៊ីមុាំអាល់–ម៉ាស្ទ់ឌី عجل الله فرجه បានឆ្លើយតបចម្លើយពួកគេ បានផ្តល់ភ័ស្តុតាងបញ្ជាក់ថាព្រះអង្គជាអ៊ីមុាំពិតប្រាកដឥតក្លែងក្លាយ ទាល់តែពួកគេជឿ ។ ព្រះអង្គបាន

បានទទួលអនិច្ចកម្ម ។ អស់លោកអ្នកប្រាជ្ញាល្បីៗទាំងនេះមិនមែនបុគ្គលដែលបានទទួលកិត្តិយសដោយបោកប្រាស់គេនោះទេ ។

បើបុគ្គលកម្មៅមួយចំនួនបដិសេធ អត្ថិភាពរបស់អ៊ីមុាំអាល់–ម៉ាស់ឌី عجل الله فرجك ចូរបុគ្គលទាំងនោះដឹងថា អ្នកនាំសារទាំងបួននាក់បានណែនាំឲ្យស្គាល់ព្រះអង្គ អស់រយៈពេល ៧០ ឆ្នាំក្នុងស្ថានភាពភ័យខ្លាច ហើយក្នុងអំឡុងពេល ៧០ ឆ្នាំ នេះ អ្នកណាថាស្គាល់អ៊ីមុាំអាល់–ម៉ាស់ឌី عجل الله فرجك អ្នកនោះអាចត្រូវសម្លាប់ ។

អ្នកនាំសារទាំងបួនរូបនេះបានតស៊ូពីម្នាក់ទៅម្នាក់ ហើយបានរក្សាទុកនូវទង់សច្ចធម៌ លុះត្រាតែអល់ឡោះហ៊ុ عز وجل បញ្ជាព្រះទន្ទ្បកាវីភ័ក្តីរបស់ព្រះអង្គ عز وجل លើសត្វលោកទាំងឡាយរបស់ព្រះអង្គ عز وجل គឺអ៊ីមុាំអាល់–ម៉ាស់ឌី عجل الله فرجك ឲ្យកំបាំងខ្លួនពីភ្នែកមនុស្ស ។ រហស្សកម្មនេះនឹងប្រព្រឹត្តតរៀងទៅលុះត្រាតែស្ថានភាពនឹងអាចធ្វើឲ្យព្រះអង្គអាចលេចខ្លួនឡើងវិញបានជាស្ថាពរ ។ នៅក្នុងអំឡុងពេលនេះ យោលតាមសក្ខីកម្មរបស់បណ្ដាអ្នកដែលបានជួបព្រះអង្គ អ៊ីមុាំមានព្រះជន្មនៅឡើយ រស់នៅជាធម្មតាដោយលាក់អត្តសញ្ញាណព្រះអង្គ ។

តែក្នុងពេលវេងចាំឱកាសល្អនឹងកើតមានឡើង ដើម្បីងើបបះបោររំដោះ



មាតាព្រះនាងជាពូជពង្សរបស់សាំអ៊ុន អ្នកជម្រះបន្សុទ្ធ ។ ថ្ងៃមួយ ព្រះចៅអធិរាជចង់អភិសេកព្រះនាងជាមួយក្មួយខ្លួន តែឈើឆ្កាងធំៗបានធ្លាក់មកក្រោមអស់យ៉ាងទាន់ហន់ ។ ព្រះចៅអធិរាជបានចាត់ទុកព្រឹត្តិការណ៍នេះជាប្រផ្នូលអាក្រក់ ក៏បានលុបចោលការអភិសេកនេះ ។

សង្គ្រាមបានផ្ទុះឡើងរវាងពួកប៊ីសង់និងពួកមុស្លីម ។ អល់ឡោះហ៊ុ عز وجل មានព្រះបំណងឲ្យណារយ៉ើសត្រូវពួកមុស្លីមចាប់ខ្លួន ហើយត្រូវនាំទៅកាន់នគរបាក់ដ្ឋាដ់ ដើម្បីដាក់លក់ជាមួយស្ត្រីច្រើននាក់ទៀត ជាសាធារណៈ ។ បាស្សៀរអាល់–អាន់ស៊័រី តាមបញ្ជាអ៊ីមុាំអាល់–ហាឌី صلوات الله عليه والسلام បានមកដល់នគរបាក់ដ្ឋាដ់ ដើម្បីទិញនារីទាសីម្នាក់ ដែលមានលក្ខណៈត្រឹមត្រូវតាមសម្ដីព្រះអង្គផ្ទាល់ ។ មកដល់ផ្សារលក់ទាសៈ បាស្សៀរបានឃើញមានតែណារយ៉ើសទេដែលមានលក្ខណៈស្រដៀងនឹងលក្ខណៈដែលអ៊ីមុាំបានប្រាប់ ។ លោកក៏បានទិញណារយ៉ើសឥតរួញរា ហើយបាននាំព្រះនាងទៅឯសាម៉ារ៉ាអ៊ុំជាមួយលោក ។ ក្នុងពេលធ្វើដំណើរ ព្រះនាងបានប្រាប់ឲ្យលោកដឹងអត្តសញ្ញាណរបស់ព្រះនាង ហើយព្រះនាងត្រូវឃុំឃាំងក្នុងស្ថានភាពណាខ្លះ ។

អ៊ីមុាំអាល់–ហាឌី صلوات الله عليه والسلام បានអភិសេកព្រះនាង ជាមួយរាជបុត្រព្រះអង្គ





បណ្ដាអ្នកតាមព្រះអង្គដែលមានវណ្ណៈផ្សេងៗគឺ៖ មានទាំងអ្នកប្រាជ្ញអ៊ីស្លាមដ៏ល្បីល្បាញ មានទាំងជនសាមញ្ញតូចតាចដែលគ្មានឈ្មោះបោះសម្លេង...

ប្រវត្តិសាស្ត្របានកត់ត្រាទុកនូវការជួបប្រទះបែបនេះច្រើនណាស់ ច្រើនដល់ថ្នាក់លែងប្រកែកបាន ។

បុគ្គលកម្លោខ្លះបាននិយាយប្រថុយប្រថាន អំពីកន្លែងលាក់ខ្លួនរបស់អ៊ីមុាំ អាល់–ម៉ាស្ទ់ឌី عجل الله فرجك ដោយគិតថាព្រះអង្គមានជីវិតរស់នៅវិសាមញ្ញដែលទីទៃពីសេចក្ដីត្រូវការរបស់ព្រះអង្គ ។ ពួកគេព្យាយាមស្វែងរកទំនាក់ទំនងរវាងហេតុការណ៍ដែលពុំមានអ្នកណាស្គាល់ ដូចជាថាសហោះជាដើម និងអ៊ីមុាំ អាល់–ម៉ាស្ទ់ឌី عجل الله فرجك ។ តែការបកស្រាយបែបនេះមិនត្រឹមតែជាការនិយាយប្រថុយដោយគ្មានហេតុផលនោះទេ ថែមទាំងផ្ទុយពីសក្ខីកម្មរបស់បុគ្គលមួយចំនួនធំដែលគួរឲ្យទុកចិត្តរៀងរហូតមកដល់ពេលនេះ ។ បុគ្គលទាំងនេះមានកិត្តិយសបានចរចាជាមួយអ៊ីមុាំ បានទទួលពរជ័យនិងការណែនាំពីព្រះអង្គ ។ ការជួបប្រទះបែបនេះមិនដែលអាក់ខានឡើយ ។ សព្វថ្ងៃអ្នកប្រាជ្ញអ៊ីស្លាមល្បីៗច្រើននាក់បានចងក្រងឡើង នូវកំណត់ហេតុស្ដីអំពីការបានជួបប្រទះព្រឹត្តិការណ៍បែបនេះ ដែលគេអាចដឹងបានបន្ទាប់ពីអស់លោកទាំងនេះ

អាស់-សាម៉ារី (علي بن محمد السمري) ។ ដំណាក់កាលនេះហៅថារហស្សកម្មតូច (គឺការកំបាំងខ្លួនរបស់អ៊ីមុាំអាល់-ម៉ាស់ហ្ឌីអស់មួយរយៈពេលតូច) ហើយបានចប់បន្ទាប់ពីអ្នកនាំសារទីបួនរបស់អ៊ីមុាំបានទទួលអនិច្ចកម្ម ។ លោកអ្នកនាំសារទីបួនបានបិទដំណាក់កាលនេះដោយផ្ទាល់ ដោយប្រកាសថាអ៊ីមុាំនឹងមិនចាត់ឲ្យមានអ្នកនាំសារទៀតទេអត់ពីលោកទៅ ហើយក្រោយពីលោកទទួលអនិច្ចកម្មទៅតំណែងនាំសារនេះត្រូវលុបចោល ។ ដំណាក់កាលថ្មីមួយទៀតនៃជីវិតអ៊ីមុាំនឹងចាប់ផ្ដើម ។

## ដំណាក់កាលទី ៣ រហស្សកម្មធំ

ដំណាក់កាលនេះបានចាប់ផ្ដើមឡើងក្នុងឆ្នាំ ៣២៩ សករាជហ៊ិជ្រ៉ោះគ្ហ៍ រហូតមកដល់សព្វថ្ងៃ ហើយនឹងមានតទៅទៀតលុះអ៊ីមុាំអាល់-ម៉ាស់ហ្ឌី عجل الله فرجك នឹងបង្ហាញខ្លួនឡើងវិញ ហើយព្រះអង្គនឹងទទួលបន្ទុកប្រតិបត្តិតុលាការសុក្រឹតរវាងមនុស្សទាំងអស់ ។ ក្នុងថ្ងៃនោះទេដែលសង្គ្រាមនឹងចប់ ជម្លោះនឹងរលត់ សន្តិភាពនិងការស្រុះស្រួលទូទៅនឹងកើតមានឡើងនៅលើផែនដីទាំងមូល នឹងមានសុភមង្គលនៅលើទូទាំងផែនដី ។

នៅក្នុងដំណាក់កាលនេះនឹងការជួបគ្នារវាងអ៊ីមុាំអាល់-ម៉ាស់ហ្ឌី عجل الله فرجك និង



អ៊ីមុាំអាល់-អាស់ការី صلوات الله عليه والسلام ។ ដូច្នេះឯងដែលដោតវាសនារបស់នារីបរិសុទ្ធរូបនេះបានក្លាយទៅជាព្រះមាតារបស់បុគ្គលអ្នកសង្គ្រោះ ដែលមនុស្សជាតិរង់ចាំអស់ច្រើនពាន់ឆ្នាំហើយ ដែលព្រះរាជសារទាំងអស់បានទាយទុករួចមកហើយ ។

# ២-ជីវប្រវត្តិរបស់អ៊ីមុាំម៉ាស់ហ្ឌី عجل الله فرجك

## ដំណាក់កាលទី ១ ជាមួយព្រះបិតាព្រះអង្គ

គេអាចចែកជីវប្រវត្តិរបស់អ៊ីមុាំអាល់-ម៉ាស់ហ្ឌី عجل الله فرجك បានជាបីដំណាក់កាលគឺៈ

- ដំណាក់កាលទីមួយជាដំណាក់កាលជីវិតរបស់ព្រះបិតា និងការថែរក្សារបស់ព្រះអង្គ ។
- ដំណាក់កាលទីពីរចាប់ផ្ដើមបន្ទាប់ពីព្រះបិតាចូលទិវង្គត ។
- ដំណាក់កាលទីបីគឺរហស្សកម្មធំរហូតមកដល់សព្វថ្ងៃនេះ ។

ដំណាក់កាលទីមួយចាប់ផ្ដើមពីកំណើតព្រះអង្គ ។ មានតែសាវកភក្ដីឯករបស់អ៊ីមុាំអាល់-អាស់ការី صلوات الله عليه والسلام ទេដែលដឹងរឿងនេះខ្លះ ពីព្រោះក្នុងរយៈពេលប្រាំឆ្នាំនេះអ៊ីមុាំបានថែរក្សាបុត្រព្រះអង្គក្នុងអាថ៌កំបាំង បានលាក់បាំង

ព្រះអង្គផុតពីភ្នែកពួកចារបុរសរបស់ស្តេចខ័លិហ្វត្រកូលអុាប៉ាស់ ។

អាជ្ញាធរសម័យនោះបានឃ្លាំមើលដំណាក់អ៊ីម៉ាំជានិច្ច ហើយបានឆែកឆេរមួយដងមួយកាលដើម្បីស្វែងរកសញ្ញាអាល់-ម៉ាស់ឌី (عجل الله فرجك) ។

## ដំណាក់កាលទី ២ បន្ទាប់ពីព្រះបិតាចូលទិវង្គត

ដំណាក់កាលនេះបានចាប់ផ្តើមឡើង ដោយការលេចឡើងជាអព្ភូតហេតុរបស់អ៊ីម៉ាំអាល់-ម៉ាស់ឌី (عجل الله فرجك) ដើម្បីមកធ្វើនមស្ការពីមុខព្រះរាជសពព្រះបិតាព្រះអង្គ និងដើម្បីបើកមុខបុគ្គលឆ្កៀតយកឱកាសអះអាងថាខ្លួនជាអ៊ីម៉ាំស្នងបង(ឬប្អូន)របស់ខ្លួន គឺឪពុកមា(ឬឪពុកធំ)របស់ព្រះអង្គ។

ដំណាក់កាលនេះមានរយៈពេល ៧០ ឆ្នាំ ។ ក្នុងអំឡុងពេល ៧០ ឆ្នាំនេះ អ៊ីម៉ាំអាល់-ម៉ាស់ឌី (عجل الله فرجك) បានរក្សាទំនាក់ទំនងជាមួយបណ្តាសាវកព្រះអង្គ តាមរយៈអ្នកនាំសារអេចិន្ត្រៃយ៍ម្នាក់ដែលសាវកទាំងអស់ស្គាល់ ។ អ្នកនាំសាររបស់អ៊ីម៉ាំអាល់-ម៉ាស់ឌី (عجل الله فرجك) មានបួននាក់ ស្នងគ្នាពីម្នាក់ទៅម្នាក់ ។ អ្នកនាំសារទីមួយគឺ អ៊ុស្ម៉ាន ប៊ិន សាអ៊ីដ (عثمان بن سعيد)។ អ្នកនាំសារទីពីរគឺ មូហាំម៉ាដ់ ប៊ិន អ៊ុស្ម៉ាន (محمد بن عثمان)។ អ្នកនាំសារទីបីគឺ អាល់-ហ៊ុសែន ប៊ិន រុះហ៍ (الحسين بن روح)។ អ្នកនាំសារទីបួនគឺ អ៊ាលី ប៊ិន មូហាំម៉ាដ់



